# Monthly Report Volume 46

October 2025

## Project Activities in October:

- 6th : Monthly Meeting with JICA HQ / Cambodia Office (online)
- 6th & 24th : Meeting with IT consultant at JICA HQ (online)
- 7th : Meeting with PTMT in BTB
- 8th–9th : INSET in BTB (Basic Nursing Skills & Communication)
- 14th & 20th & 31st : Meeting with HRDD IT team
- 21st & 23rd: Meeting with PTMT in KC
- 22nd –23rd : INSET in KC (Nursing Ethics & Communication)
- 30th : Meeting with Nagasaki Univ. research team

## First INSET in Kampong Cham and Second Session in Battambang

The In-Service Training (INSET) for nurses has continued to make consistent progress in both pilot provinces, Battambang and Kampong Cham.

In Battambang, the second session was held from 8th to 9th, covering Basic Nursing Skills (2 days, 30 participants) and Communication (2 days, 33 participants). As this was the second implementation in the province, the Provincial Training Management Team (PTMT) carried out the preparation and facilitation more smoothly than in the previous round, reflecting the steady progress of the handover of training management from the Project to the provincial team.



Communication course - Participants Engaged in the Lecture



BNS course - Physical Assessment Practice

In Kampong Cham, the first INSET was conducted from 22nd to 23rd, featuring Nursing Ethics (1.5 days, 27 participants) and Communication (2 days, 33 participants). The courses were organized at two venues—the Provincial Health Department and the Provincial Hospital—which posed some coordination challenges for the PTMT. However, after the training, the PTMT held a review meeting with the Project team to share the challenges and identify practical measures for improvement. The next INSET courses are scheduled for late November, and further enhancement in the training management is expected based on the lessons learned from this initial experience.



Communication Course Participants



Nursing Ethics Course – Group Work Session

## Meetings on the E-Learning Platform with MoH IT Team and JICA HQ Consultant

The Project held a series of meetings with both the JICA Headquarters IT consultant and the Ministry of Health (MoH) IT teams to discuss the improvement and future management of the E-Learning Platform (ELP).

Two meetings with the JICA HQ IT consultant were held on 6th and 24th. The discussions reviewed the current operation of the E-Learning Platform (ELP), which has been in use since September 2024, supporting the third round of the Training of Trainers (ToT3) conducted between December 2024 and June 2025, as well as the ongoing INSET implementation in the pilot provinces. Through actual operation, the Project and the Human Resource Development Department (HRDD) identified several functions that require technical modification. The consultant has been assisting the Project in analyzing these issues, and, in coordination with HRDD and the MoH IT team, a plan for system improvement is expected to be finalized around the end of this year.

In addition, three meetings were held with the HRDD IT team on 14th, 20th, and 31st to discuss usability, team roles, and the operation and management of the ELP. The last meeting included newly assigned IT officers from the Department of Digital Health and Department of Mental Health and Substance Abuse, marking the beginning of cross-departmental collaboration under the Ministry's shared direction for the sustainable management of the platform.



ELP Registration Support During INSET in KC



Meeting with HRDD IT Team

## UPCOMING ACTIVITIES IN NOVEMBER

- 10th : Monthly Meeting with JICA HQ / Cambodia Office (online)
- 12th–13th : INSET in BTB (Nursing Process Application & Nursing Research)
- 23rd Nov.–5th Dec.: Dispatch of Nursing Education Short-Term Expert
- 26th–27th : INSET in KC (Nursing Ethics & Nursing Management & Leadership)


## CONTACT INFORMATION

**Email:** info@jicastrings.com

**Project Office:**

- **Ministry of Health (MoH)**

Department of Human Resource Development (HRDD)
No. 80, Samdach Penn Nouth Blvd (289), Sangkat Beoungkak 2, Tuol Kork District, Phnom Penh

- **National Maternal and Child Health Center (NMCHC)**

N° 31A, Rue de France (St. 47), Sangkat Sras Chork, Daun Penh District, Phnom Penh


Scan here to find out more about us:

JICA's FB Page

Project's Homepage

# Monthly Report Volume 46

**តុលា ២០២៥**

## សកម្មភាពគម្រោងប្រចាំខែតុលា៖

- ថ្ងៃទី៦៖ កិច្ចប្រជុំប្រចាំខែជាមួយ JICA HQ/Cambodia Office
- ថ្ងៃទី៦ និងទី២៤៖ កិច្ចប្រជុំជាមួយទីប្រឹក្សាផ្នែកIT នៅ JICA HQ (អនឡាញ)
- ថ្ងៃទី៧៖ កិច្ចប្រជុំជាមួយក្រុម PTMT នៃខេត្តបាត់ដំបង
- ថ្ងៃទី៨ ដល់ទី៩៖ ការបណ្តុះបណ្តាល INSET ក្នុងខេត្តបាត់ដំបង
  វគ្គជំនាញមូលដ្ឋាន នៃការថែទាំ និងវគ្គការប្រាស្រ័យទាក់ទង
- ថ្ងៃទី១៤ ទី២០ និងទី៣១៖ កិច្ចប្រជុំជាមួយនឹងផ្នែកIT នៃ HRDD
- ថ្ងៃទី២១ និងទី២៣៖ កិច្ចប្រជុំជាមួយក្រុម PTMT នៃខេត្តកំពង់ចាម
- ថ្ងៃទី២២ ដល់ទី២៣៖ ការបណ្តុះបណ្តាល INSET ក្នុងខេត្តកំពង់ចាម
  វគ្គសីលធម៌ នៃការថែទាំ និងវគ្គការប្រាស្រ័យទាក់ទង
- ថ្ងៃទី៣០៖ កិច្ចប្រជុំជាមួយក្រុមស្រាវជ្រាវមកពីសាកលវិទ្យាល័យ ណាហ្គាសាគី

## វគ្គបណ្តុះបណ្តាលក្នុងពេលបម្រើការងារសម្រាប់គិលានុបដ្ឋាក (INSET) ជាលើកដំបូងនៅខេត្តកំពង់ចាម និងជាលើកទីពីរនៅខេត្តបាត់ដំបង

វគ្គបណ្តុះបណ្តាលក្នុងពេលបម្រើការងារសម្រាប់គិលានុបដ្ឋាក (INSET) បានបន្តធ្វើឱ្យមានវឌ្ឍនភាពជាប់លាប់នៅក្នុងខេត្តគោលដៅទាំងពីរគឺ ខេត្តបាត់ដំបង និងខេត្តកំពង់ចាម។

នៅខេត្តបាត់ដំបង វគ្គបណ្តុះបណ្តាលជាលើកទីពីរ ត្រូវបានធ្វើឡើងនៅថ្ងៃទី៨ ដល់ទី៩ សម្រាប់វគ្គជំនាញមូលដ្ឋាន នៃការថែទាំ (រយៈពេល២ថ្ងៃ មានសិក្ខាកាមចូលរួម ៣០នាក់) និងវគ្គការប្រាស្រ័យទាក់ទង (រយៈពេល២ថ្ងៃ មានសិក្ខាកាមចូលរួម ៣៣នាក់)។ ដោយសារនេះជាការបណ្តុះបណ្តាលជាលើកទី២ក្នុងខេត្ត ក្រុមការងារគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់ខេត្ត (PTMT) បានអនុវត្តការរៀបចំ និងការសម្របសម្រួលបានយ៉ាងរលូនជាងវគ្គមុន ដោយឆ្លុះបញ្ចាំងពីវឌ្ឍនភាពនៃការទទួលខុសត្រូវរបស់ថ្នាក់ខេត្តក្រោយការប្រគល់ការគ្រប់គ្រងការបណ្តុះបណ្តាលពីគម្រោង ទៅក្រុមការងារថ្នាក់ខេត្ត។



BNS course - Physical Assessment Practice



Communication course - Participants Engaged in the Lecture

នៅខេត្តកំពង់ចាម វគ្គបណ្តុះបណ្តាលជាលើកទីមួយបានធ្វើឡើងនៅថ្ងៃទី២២ ដល់ទី២៣ សម្រាប់ វគ្គសីលធម៌ នៃការថែទាំ (រយៈពេល១.៥ថ្ងៃ មានសិក្ខាកាមចូលរួម ២៧នាក់) និងវគ្គការប្រាស្រ័យទាក់ទង (រយៈពេល២ថ្ងៃ មានសិក្ខាកាមចូលរួម ៣៣នាក់)។ វគ្គបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើងនៅទីតាំងចំនួនពីរ គឺមន្ទីរសុខាភិបាលខេត្ត និងមន្ទីរពេទ្យខេត្ត ដែលបានជួបនូវបញ្ហាប្រឈមមួយចំនួនក្នុងការសម្របសម្រួលសម្រាប់ ក្រុម PTMT។ ទោះយ៉ាងណាក៏ដោយ បន្ទាប់ពីបញ្ចប់ការបណ្តុះបណ្តាល ក្រុម PTMT បានប្រជុំជាមួយក្រុមការងារគម្រោង ដើម្បីចែករំលែកបញ្ហាប្រឈម និងកំណត់វិធានការជាក់ស្តែងសម្រាប់ការកែលម្អ វគ្គបណ្តុះបណ្តាលបន្ទាប់របស់ INSET ដែលត្រូវបានកំណត់នៅចុងខែវិច្ឆិកា ហើយការពង្រឹងបន្ថែមទៀតនៅក្នុងការគ្រប់គ្រងការបណ្តុះបណ្តាលត្រូវបានរំពឹងទុកដោយផ្អែកលើបទពិសោធន៍ដែលបានជួបប្រទះក្នុងវគ្គបណ្តុះបណ្តាលដំបូងនេះ។




Communication Course Participants



Nursing Ethics Course – Group Work Session

## កិច្ចប្រជុំស្តីពី វេទិកា E-Learning ជាមួយ មន្ត្រីផ្នែក IT នៃក្រសួងសុខាភិបាល និងទីប្រឹក្សាផ្នែក IT នៃទីស្នាក់ការកណ្តាលរបស់ JICA

គម្រោងបានរៀបចំកិច្ចប្រជុំជាបន្តបន្ទាប់ជាមួយទីប្រឹក្សា IT ទីស្នាក់ការកណ្តាលរបស់ JICA និងក្រុម IT របស់ក្រសួងសុខាភិបាល (MoH) ដើម្បីពិភាក្សាអំពីការធ្វើឱ្យប្រសើរឡើង និងការគ្រប់គ្រងនាពេលអនាគតនៃ E-Learning Platform (ELP)។

កិច្ចប្រជុំចំនួនពីរដងជាមួយទីប្រឹក្សា JICA HQ IT ត្រូវបានធ្វើឡើងនៅថ្ងៃទី៦ និងថ្ងៃទី២៤។ ការពិភាក្សាបានពិនិត្យឡើងវិញនូវប្រតិបត្តិការបច្ចុប្បន្ននៃវេទិកា E-Learning Platform (ELP) ដែលបានប្រើប្រាស់តាំងពីខែកញ្ញា ឆ្នាំ២០២៤ ដោយគាំទ្រដល់វគ្គបណ្តុះបណ្តាលគ្រូបង្គោលវគ្គបី (ToT៣) ដែលធ្វើឡើងនៅចន្លោះខែធ្នូ ឆ្នាំ២០២៤ ដល់ខែមិថុនា ឆ្នាំ២០២៥ ក៏ដូចជាការអនុវត្ត INSET ដែលកំពុងបន្តនៅក្នុងខេត្តគោលដៅទាំងពីរ។ តាមរយៈប្រតិបត្តិការជាក់ស្តែងបុគ្គលិកគម្រោង និងមន្ត្រីនៃនាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស (HRDD) បានកំណត់មុខងារជាច្រើនដែលទាមទារការកែសម្រួលផ្នែកបច្ចេកទេស។ ទីប្រឹក្សាបាននិងកំពុងជួយគម្រោងក្នុងការវិភាគបញ្ហាទាំងនេះ ហើយដោយមានការសម្របសម្រួលជាមួយមន្ត្រីនៃនាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស (HRDD) និងមន្ត្រីផ្នែក IT របស់ក្រសួងសុខាភិបាល ដូច្នេះផែនការសម្រាប់ការកែលម្អប្រព័ន្ធត្រូវបានគេរំពឹងថានឹងបញ្ចប់នៅចុងឆ្នាំនេះ។

លើសពីនេះទៀត កិច្ចប្រជុំចំនួនបីដង ត្រូវបានធ្វើឡើងជាមួយមន្ត្រី IT នៃ HRDD នៅថ្ងៃទី១៤ ទី២០ និងថ្ងៃទី៣១ ដើម្បីពិភាក្សាអំពីលទ្ធភាពប្រើប្រាស់ តួនាទីក្រុម និងប្រតិបត្តិការ និងការគ្រប់គ្រងវេទិកា (ELP)។ កិច្ចប្រជុំចុងក្រោយរួមមានមន្ត្រី IT មកពីនាយកដ្ឋានសុខាភិបាលឌីជីថលដែលទើបនឹងបង្កើតថ្មី និងមន្ត្រីIT មកពីនាយកដ្ឋានសុខភាពផ្លូវចិត្ត និងការបំពានគ្រឿងញៀន ដែលបង្ហាញពីការចាប់ផ្តើមនៃកិច្ចសហការឆ្លងនាយកដ្ឋានក្រោមការដឹកនាំរួមគ្នារបស់ក្រសួងសុខាភិបាលសម្រាប់ការគ្រប់គ្រងប្រកបដោយនិរន្តរភាពនៃវេទិកានេះ។



ELP Registration Support During INSET in KC



Meeting with HRDD IT Team

## សកម្មភាពនាពេលខាងមុខក្នុងខែវិច្ឆិកា

- ថ្ងៃទី១០៖ កិច្ចប្រជុំប្រចាំខែជាមួយ JICA HQ/Cambodia Office
- ថ្ងៃទី១២ ដល់ទី១៣៖ ការបណ្តុះបណ្តាល INSET ក្នុងខេត្តបាត់ដំបង
  វគ្គការប្រើប្រាស់ដំណើរការ នៃការថែទាំជំងឺ និងវគ្គការស្រាវជ្រាវផ្នែកថែទាំ
- ថ្ងៃទី២៣ ខែវិច្ឆិកា ដល់ទី៥ ខែធ្នូ៖ អ្នកជំនាញផ្នែកអប់រំគិលានុបដ្ឋាកចូលរួមក្នុងសកម្មភាពគម្រោងរយៈពេលខ្លី
- ថ្ងៃទី២៦ ដល់ទី២៧៖ ការបណ្តុះបណ្តាល INSET ក្នុងខេត្តកំពង់ចាម
  វគ្គសីលធម៌ នៃការថែទាំ និងវគ្គការគ្រប់គ្រងការថែទាំ និងភាពជាអ្នកដឹកនាំ


## CONTACT INFORMATION

**Email:** info@jicastrings.com

**Project Office:**

- **Ministry of Health (MoH)**
  Department of Human Resource Development (HRDD)
  No. 80, Samdach Penn Nouth Blvd (289), Sangkat Beoungkak 2, Tuol Kork District, Phnom Penh
- **National Maternal and Child Health Center (NMCHC)**
  N° 31A, Rue de France (St. 47), Sangkat Sras Chork, Daun Penh District, Phnom Penh


Scan here to find out more about us:

JICA's FB Page

Project's Homepage